ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

**សាលក្រមរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខ ៖ ៧៩១
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០
សញ្ញាណនៃរឿងក្តី ៖ បណ្តឹងលែងលះ
សាលក្រមរដ្ឋប្បវេណីលេខ៖ ០៥ (ឌ)
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ដើមចោទ÷**

+ឈ្មោះ [redacted] សុខគៀន ភេទស្រី កើតឆ្នាំ១៩៨០ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិពោង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អុន (ស្លាប់) ម្ដាយឈ្មោះ[redacted]សុខកា(ស្លាប់) ប្ដីឈ្មោះ [redacted]ហាក់លាង មានកូន០២នាក់ ជានីតិជន។

+មានអ្នកតំណាងដោយអាណត្តិលោក [redacted]អត្តលេខ:២០៣២T, លោក [redacted] អត្តលេខ:០២៣, លោក [redacted]អត្តលេខ:២០៣១T, លោក [redacted]អត្តលេខ:១១២២, លោក [redacted]អត្តលេខ:១០៨៥, លោក [redacted]អត្តលេខ:២០៤២T, លោក[redacted]អត្តលេខ:៦៦៨ និងលោក [redacted] អត្តលេខ១៩៦៣T ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

ចុងចម្លើយឈ្មោះ [redacted]ហាក់លាង ភេទប្រុស កើតឆ្នាំ១៩៨៤ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅ[redacted]

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១.១. សុំលែងលះប្តីឈ្មោះ [redacted] ហាក់លាង ភេទប្រុស ជាតិខ្មែរ ។

១.២. សុំសិទ្ធិគ្រប់គ្រងកូនស្រីចំនួន០២នាក់ ឈ្មោះ [redacted] ស្រីពេជ្រ កើតឆ្នាំ២០០៥ និង ឈ្មោះ [redacted] មួយស៊ាំង កើតឆ្នាំ២០១១ ។

១.៣. សុំបែងចែកទ្រព្យសម្បត្តិរួម ។

**២. អង្គហេតុ និងចំណុចវិវាទ**

២.១. រឿងក្តីនេះដើមចោទបានអះអាងថា៖ នៅក្នុងរឿងនេះ ខ្ញុំសុំរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ទុកជាបានការដដែល ។ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ហាក់លាង ត្រឹមត្រូវតាមប្រពៃណី កាលពីឆ្នាំ២០០៤ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ២៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ចេញដោយមន្ត្រីអាត្រានុកូលដ្ឋានឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល។ ចាប់តាំងពីខ្ញុំ និងចុងចម្លើយរស់នៅជាមួយគ្នាជាប្តីប្រពន្ធមក គឺមិនសូវជាមានសុភមង្គលក្នុងគ្រួសារឡើយ ព្រោះប្តីរបស់ខ្ញុំឈ្មោះ [redacted] ហាក់លាង មិនសូវយកចិត្តទុកដាក់រកស៊ី ធ្វើការងារអ្វីឡើយ គិតតែពីផឹកស្រាស្ទើរតែរាល់ថ្ងៃ ថែមទាំងប្រើប្រាស់អំពើហិង្សាមកលើរូបខ្ញុំ និងកូនទៀតផង ។ កន្លងមកខ្ញុំ និងប្តីធ្លាប់ទៅដោះស្រាយគ្នានៅសាលាឃុំផងដែរ ប៉ុន្តែមិនត្រូវរ៉ូវគ្នាវិញឡើយ។ នៅពេលនេះ ខ្ញុំអស់មនោសញ្ចេតនាជាមួយចុងចម្លើយទៀតហើយ។ ការរស់នៅជាមួយចុងចម្លើយកន្លងមក គឺមានកូនស្រីក្នុងបន្ទុកចំនួន០២នាក់ គឺកូនស្រីទី១ ឈ្មោះ [redacted] ស្រីពេជ្រ កើតឆ្នាំ២០០៥ និងកូនស្រីទី២ឈ្មោះ [redacted] មួយស៊ាំង។ ចំពោះទ្រព្យសម្បត្តិរួមមាន៖ ក្របី ០៧ក្បាល, ម៉ូតូ០១គ្រឿងម៉ាក សង់ទ្រឹម ស៊េរី០១៧, ខ្សែដៃមាសទម្ងន់០៥ជី, ខ្សែករមាស ទម្ងន់០៤ជី។ ចំណែកបំណុលរួមគ្មានឡើយ។

នៅក្នុងរឿងនេះ ខ្ញុំសុំលែងលះជាមួយចុងចម្លើយ និងសុំសិទ្ធិមានអំណាចមេបាលើកូនស្រីទាំងពីរនាក់ខាងលើ។ ចំពោះប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ខាងលើ គឺខ្ញុំមិនទាមទារពីចុងចម្លើយឡើយ។

ចំពោះទ្រព្យសម្បត្តិរួមដែលរៀបរាប់ខាងលើ ខ្ញុំសុំបែងចែកក្របីម្នាក់បីក្បាល, រីឯម៉ូតូម៉ាកសង់ទ្រឹម ០១គ្រឿង ខ្ញុំមិនទាមទារឡើយ គឺសុំប្រគល់ឲ្យចុងចម្លើយចុះ ។ ចំណែកខ្សែដៃមាសទម្ងន់០៥ជី និងខ្សែករមាស ទម្ងន់ ០៤ជី ខ្ញុំសុំយកតែម្នាក់ឯង

នៅក្នុងរឿងនេះ ខ្លួនសុំឲ្យតុលាការសម្រេចតាមការស្នើសុំផង ព្រោះខ្លួនអស់មនោសញ្ចេតនាជាមួយចុងចម្លើយហើយ ។

**ចុងចម្លើយបានឆ្លើយតបទៅនឹងការអះអាងរបស់ដើមចោទថា៖** នៅក្នុងរឿងនេះ ការដែលដើមចោទអះអាងថា ខ្លួនបានប្រើប្រាស់អំពើហិង្សាទៅលើគាត់ គឺមិនពិតឡើយ ខ្លួនមិនដែលមានវាយទៅលើដើមចោទឡើយ មានតែដើមចោទប៉ុណ្ណោះដែលធ្លាប់វាយមកលើរូបខ្លួន។ ចំពោះការអះអាងថា ខ្លួនមិនបានជួយរកស៊ី គឺមិនពិតឡើយ ព្រោះខ្លួននិងប្រពន្ធខិតខំប្រឹងប្រែងរកស៊ី ធ្វើការងារជាមួយគ្នាណាស់ មិនដូចការអះអាងខាងលើឡើយ។ នៅក្នុងរឿងនេះ ខ្លួនមិនព្រមលែងលះជាមួយដើមចោទឡើយ ព្រោះខ្លួននៅស្រលាញ់ដើមចោទនៅឡើយ។ ចំពោះម៉ូតូ គឺខ្លួនមិនទាមទារឡើយ គឺខ្លួនសុខចិត្តទុកឲ្យកូន។ ចំណែកខ្សែដៃ និងខ្សែក ដែលដើមចោទទាមទារ ខ្លួនក៏មិនព្រមតាមការទាមទារដែរ។ ចំពោះកូនទាំងពីរដែលដើមចោទសុំសិទ្ធិអំណាចមេបា គឺខ្លួនព្រមប្រគល់ឲ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។ ចំពោះសត្វក្របីសរុបពិតជាមានប្រាំពីរក្បាលពិតប្រាកដមែន ។

**២.២. អង្គហេតុដែលគ្មានវិវាទ**

កាលពីអំឡុងឆ្នាំ២០០៥ ដើមចោទឈ្មោះ [redacted] សុខគឿន បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ហាក់លាង ត្រឹមត្រូវតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៤៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ត្រឹមត្រូវតាមផ្លូវច្បាប់។ នៅក្នុងរឿងនេះ ដើមចោទទាមទារ០៣ (បី) ចំណុច តែចុងចម្លើយឯកភាព០១(មួយ) ចំណុច គឺការប្រគល់សិទ្ធិអំណាចមេបាលើកូនស្រីទាំងពីរទៅដើមចោទ ។ ឯការលែងលះ និងបែងចែកទ្រព្យសម្បត្តិរួម គឺចុងចម្លើយមិនយល់ព្រមតាមការទាមទារឡើយ ។

**២.៣. ការអះអាងរបស់ភាគីទាក់ទងនឹងចំណុចវិវាទ**

**២.៣.១. ចំណុចវិវាទទី ១**

**ក. ការអះអាងរបស់ដើមចោទ**

ដើមចោទរស់នៅជាមួយចុងចម្លើយតាំងពីអំឡុងឆ្នាំ២០០៥ មិនដែលមានសុភមង្គលក្នុងគ្រួសារឡើយ ព្រោះចុងចម្លើយមិនជួយធ្វើការងារ ប្រកបរបររកស៊ីអ្វីឡើយ គិតតែដើរផឹកស្រា ហើយប្រើប្រាស់អំពើហិង្សាមកលើប្រពន្ធ និងកូនទៀតផង

ខ. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយមិនព្រមលែងលះជាមួយដើមចោទឡើយ ព្រោះចុងចម្លើយនៅមានមនោសញ្ចេតនាជាមួយដើមចោទនៅឡើយ។ ចំពោះការអះអាងថា ខ្លួនមិនបានជួយរកស៊ី គឺមិនពិតឡើយ ព្រោះខ្លួន និងប្រពន្ធខិតខំប្រឹងប្រែងរកស៊ី ធ្វើការងារជាមួយគ្នាណាស់ មិនដូចការអះអាងខាងលើឡើយ ។ ការដែលដើមចោទអះអាងថា ខ្លួនបានប្រើប្រាស់អំពើហិង្សាទៅលើគាត់ គឺមិនពិតឡើយ ខ្លួនមិនដែលបានវាយទៅលើដើមចោទឡើយ មានតែដើមចោទប៉ុណ្ណោះដែលធ្លាប់វាយមកលើរូបខ្លួន។

គ. អង្គហេតុវិវាទ

តើមូលហេតុលែងលះដែលដើមចោទទាមទារខាងលើមានភាពត្រឹមត្រូវដែរឬទេ?

២.៣.២. ចំណុចវិវាទទី២

ក. ការអះអាងរបស់ដើមចោទ

ដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាមានទ្រព្យសម្បត្តិរួមដូចជា ក្របីចំនួន ០៧(ប្រាំពីរ) ក្បាល, ម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម ស៊េរីឆ្នាំ២០១៧ ពាក់ស្លាកលេខ ភ្នំពេញ 1GN-7350, ខ្សែដៃមាសទម្ងន់០៥ជី និងខ្សែករមាសទម្ងន់០២ជី ។ នៅក្នុងរឿងនេះ ដើមចោទព្រមប្រគល់ម៉ូតូ០១គ្រឿងឲ្យទៅចុងចម្លើយ និងសុំទាមទារខ្សែដៃមាសទម្ងន់០៥ជី និងខ្សែករមាសទម្ងន់០២ជី មកធ្វើជាកម្មសិទ្ធិ ។

ខ. ការអះអាងរបស់ចុងចម្លើយ

ចំពោះទ្រព្យសម្បត្តិរួមជាម៉ូតូ គឺខ្លួនមិនទាមទារឡើយ គឺខ្លួនសុខចិត្តទុកឲ្យកូន។ ចំណែកខ្សែដៃ និងខ្សែក ដែលដើមចោទទាមទារ ខ្លួនក៏មិនព្រមតាមការទាមទារដែរ។

គ. អង្គហេតុវិវាទ

តើការទាមទារទ្រព្យសម្បត្តិរួមរបស់ដើមចោទមានភាពត្រឹមត្រូវដែរ ឬទេ?

**សំអាងហេតុ**

១. ការវិនិច្ឆ័យអំពីចំណុចវិវាទ

មូលហេតុដែលដើមចោទសុំលែងលះជាមួយចុងចម្លើយ ព្រោះការរស់នៅជាមួយគ្នាកន្លងមក ចុងចម្លើយមិនជួយធ្វើការងារ ប្រកបរបររកស៊ីឡើយ គិតតែដើរផឹកស្រា ប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាមួយចុងចម្លើយទៀតហើយ ។ ឃើញថា ការអះអាងលើការទាមទារចំពោះចំណុចវិវាទខាងលើ ដើមចោទ



Scanned with CamScanner

ពិតជាទទួលរងនូវការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ដូចដែលដើមចោទបានដាក់ភស្តុតាងជូនតុលាការពិនិត្យប្រាកដមែន ដូចនេះ ទើបធ្វើឲ្យការរស់នៅជាមួយគ្នាមិនចុះសម្រុង និងអស់មនោសញ្ចេតនាជាប្តីប្រពន្ធបន្តទៀតហើយ ដែលធ្វើឲ្យទំនាក់ទំនងអាពាហ៍ពិពាហ៍មិនអាចធ្វើបដិទានឡើងវិញបាន ។ ហេតុដូច្នេះ គប្បីតុលាការពិចារណាអំពីមូលហេតុនៃការលែងលះស្របតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២. ការវិនិច្ឆ័យអំពីការទាមទារ

**យល់ឃើញថា** ដើមចោទ និងចុងចម្លើយ ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាំងពីអំឡុងឆ្នាំ២០០៥ តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍៤៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន ។

**យល់ឃើញថា** ដើមចោទអស់មនោសញ្ចេតនាជាមួយចុងចម្លើយទៀតហើយ បានសុំឲ្យតុលាការសម្រេចលែងលះដើមចោទជាមួយចុងចម្លើយ ព្រោះចុងចម្លើយមិនជួយរកស៊ី គិតតែដើរផឹកស្រា និងប្រើប្រាស់អំពើហិង្សាមកលើដើមចោទ និងកូន ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ។ ចំណុចនេះ គប្បីតុលាការពិចារណាតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

**យល់ឃើញថា** ក្នុងអំឡុងពេលដែលដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាជាប្តីប្រពន្ធមានកូនក្នុងបន្ទុកចំនួន០២(ពីរ) នាក់ គឺឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតឆ្នាំ២០០៥ មានសំបុត្របញ្ជាក់កំណើតលេខ២៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ និងឈ្មោះ លាង មួយស៊ាំង ភេទស្រី កើតឆ្នាំ២០១១ មានសំបុត្របញ្ជាក់កំណើតលេខ២៧៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសំបូរមាស ប្រាកដមែន ។

**យល់ឃើញថា** ដើមចោទស្នើសុំសិទ្ធិអំណាចមេបាលើកូនស្រីទាំង០២ (ពីរ) នាក់ខាងលើ ចំណែកចុងចម្លើយព្រមព្រៀងប្រគល់សិទ្ធិមានអំណាចមេបាលើកូនទាំងពីរឲ្យទៅដើមចោទ ។ ឃើញថា ចំណុចនេះ គប្បីតុលាការសម្រេចអំពីអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់តាមការពិភាក្សារបស់ឪពុកម្តាយ ស្របតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

**យល់ឃើញថា** តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ បានបញ្ជាក់ថា ពិតជាមានទ្រព្យសម្បត្តិរួមដូចជា គោបីចំនួន០៧(ប្រាំពីរ) ក្បាល, ម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម



Scanned with CamScanner

សេរីឆ្នាំ២០១៧ ពាក់ស្លាកលេខ ភ្នំពេញ 1GN-7350, ខ្សែដៃមាសទម្ងន់០៥ជី និងខ្សែករមាសទម្ងន់០៤ជី ប្រាកដមែន។ ដោយហេតុថា ចំពោះទ្រព្យសម្បត្តិរួមខាងលើ ភាគីមិនអាចពិភាក្សាគ្នាបានឡើយ។ ដូចនេះ គប្បីតុលាការពិចារណាតាមបញ្ញត្តិមាត្រា៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ។

៣. ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ហេតុដូច្នេះ តុលាការ ធ្វើការវិនិច្ឆ័យដូចខាងក្រោម ៖

**សេចក្តីសម្រេចបញ្ចប់**

១. ទទួលស្គាល់ពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សុខកឿន ភេទស្រី ទុកជាត្រឹមត្រូវ ។

២. ឲ្យដើមចោទឈ្មោះ [redacted] សុខកឿន ភេទស្រី ជាតិខ្មែរ កើតឆ្នាំ១៩៨០ លែងលះពីចុងចម្លើយឈ្មោះ [redacted] លាងហាក់ ភេទប្រុស ជាតិខ្មែរ កើតឆ្នាំ១៩៨៤ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ៤៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ។

៣. កំណត់ឲ្យដើមចោទឈ្មោះ [redacted] សុខកឿន មានសិទ្ធិអំណាចមេបាលើកូនស្រីទាំងពីរនាក់គឺ៖

ក. ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី កើតឆ្នាំ២០០៥ ជាតិខ្មែរ ។

ខ. ឈ្មោះ [redacted] មួយស៊ាំង ភេទស្រី កើតឆ្នាំ២០១១ ជាតិខ្មែរ ។

អ្នកដែលមិនមានអំណាចមេបាលើកូនអាចចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបានស្របតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។

៤.ការបែងចែកទ្រព្យសម្បត្តិរួម៖

ក. ប្រគល់៖ម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម សេរីឆ្នាំ២០១៧ ពាក់ស្លាកលេខ ភ្នំពេញ 1GN-7350 និងក្របីចំនួន០៣ (បី) ក្បាល ឲ្យទៅចុងចម្លើយឈ្មោះ ទ្រី លាងហាក់ ជាអ្នកមានសិទ្ធិគ្រប់គ្រង ។

ខ. ប្រគល់៖ ខ្សែដៃមាសទម្ងន់០៥ជី, ខ្សែករមាសទម្ងន់០៤ជី និងសត្វក្របីចំនួន០៤ (បួន) ក្បាល ឲ្យទៅដើមចោទឈ្មោះ [redacted] សុខកឿន ជាអ្នកមានសិទ្ធិគ្រប់គ្រង ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ នៅចំពោះមុខដើមចោទ, អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ និងចំពោះមុខចុងចម្លើយ



Scanned with CamScanner

ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ថ្ងៃច័ន្ទ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្តាល, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១

ចៅក្រម

ហត្ថលេខា និងត្រា៖ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

នៅខេត្តកណ្តាល, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]